# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ  សាសនា  ព្រះមហាក្សត្រ

************************

# គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

# (M-IWRMP)

# កម្ពុជា: គម្រោងគ្រប់គ្រងសង្គម  និងបរិស្ថាន
# (ESMF)

១៥ តុលា  ២០១០

# អារម្ភកថា

គម្រោងគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) សំរាប់ព្រះរាជាណាចក្រកម្ពុជាគឺត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានគ្រឹះនៃលទ្ធផលនានាពីការសិក្សាសង្គម និងបរិស្ថានតំបូង។ វានឹងត្រូវបានអនុវត្តនូវរាល់ការវិនិយោគនានាដើម្បីផ្តល់នូវហិរញ្ញវត្ថុតាមរយៈធនាគារពិភពលោកសំរាប់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRM)។

ផ្នែកគ្រប់គ្រងគម្រោង និងផ្នែកអនុវត្តគម្រោងនីមួយៗរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទួលខុសត្រូវដើម្បីធានាថាស្របទៅតាមគម្រោងគ្រប់គ្រងសង្គម និងបរិស្ថាន ដោយរួមមានទាំងការរក្សាទុកនូវឯកសារសមរម្យនៅក្នុងសំណុំរឿងរបស់គម្រោងដើម្បីងាយស្រួលក្នុងការពិនិត្យឡើងវិញតាមរយៈធនាគារពិភពលោក។

ឯកសារនេះគឺត្រូវបានគេចាត់ទុកថាជាឯកសារមួយ និងអាចត្រូវបានបំពេញបន្ថែម និងផ្លាស់ប្តូរស្រដៀងគ្នាជាមួយការប្រែប្រួលនូវស្ថានភាព វីព្រំដែននៃសកម្មភាពនានា។ កិច្ចពិគ្រោះយោបល់ចុងក្រោយជាមួយធនាគារពិភពលោក និងការសំអាតនៃគម្រោងគ្រប់គ្រងសង្គម និងបរិស្ថានដែលបានសង្ខេបនឹងជាការចាំបាច់។

# គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

## (M-IWRM)

## កម្ពុជា: គម្រោងគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF)

### មាតិកាអត្ថបទ

ទំព័រ


I. សេចក្តីផ្តើម ………………………………………………………………...៤

II. សេចក្តីលំអិតនៃគម្រោង ……………………………………………………. ៤

III. នីតិវិធីនៃការសម្រាល និងបញ្ហាសុវត្ថិភាពសំខាន់នានា …………………….. …….៦

IV. ដំណើការឆ្លុះបញ្ចាំងនៃសុវត្ថិភាព ………………………………………….....៨

V. ការអនុវត្ត និងរៀបចំការតាមដាន …………...……….…………………………១០

តារាងទី ១. សេចក្តីណែនាំស្តីពីបញ្ហាសុវត្ថិភាពមួយចំនួន និងសកម្មភាពនានា

ក្រាហ្វិកទី ១. ក្រាហិក្វដើម្បីកំណត់នូវនីតិវិធីសុវត្ថិភាព

ឧបសម្ព័ន្ធទី ១: បញ្ជីអវិជ្ជមាននៃសកម្មភាពដែលបានហាមឃាត់

ឧបសម្ព័ន្ធទី ២: វិធានការសម្រាលមួយចំនួន និងការអនុវត្តវិស្វកម្មល្អៗមួយចំនួន

ឧបសម្ព័ន្ធទី 3: ផែនការគ្រប់គ្រងសត្វចង្រៃដែលមានលក្ខណៈងាយស្រួល

## I. សេចក្តីផ្តើម

១. គម្រោងគ្រប់គ្រងសង្គម និងសុវត្ថិភាពសង្គម និងបរិស្ថានត្រូវបានរៀបចំគឺត្រូវបានដើម្បីអភិវឌ្ឍន៍ដោយយោងទៅលើលទ្ធផលនានាពីការសិក្សាសង្គម និងបរិស្ថានតំបូងដើម្បីធ្វើអោយមានផលប៉ះពាល់ជាអវិជ្ជមានសង្គម និងបរិស្ថានដែលអាចកើតឡើងដោយសារការអនុវត្តនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដែលតម្រូវដោយគោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោកស្តីពីការវាយតម្លៃបរិស្ថាន (OP4.01)។ គម្រោងគ្រប់គ្រងសង្គម និងសុវត្ថិភាពសង្គម និងបរិស្ថានពិពណ៌មាននូវរបៀបដោះស្រាយបញ្ហាសុវត្ថិភាពមួយចំនួនតាមរយៈការសង្ខេប (១). ប្រភេទនៃសកម្មភាពនានាដែលនឹងមិនត្រូវបានគាំទ្រដោយ គម្រោងតាមរយៈ " បញ្ជីនៃផលប៉ះពាល់ " (២). ជំហាននានានៃការឆ្លុះបញ្ចាំងនូវសុវត្ថិភាព និងការវាយតម្លៃ ដើម្បីកំណត់នូវសក្តដានុពលបញ្ហាសុវត្ថិភាពនានា (បរិស្ថាន និងសង្គម) ដោយរួមទាំងនីតិវិធីជាក់លាក់ និងការរៀបចំឯកសារនានា និងឱកាសដើម្បីបង្កើនផលប៉ះពាល់ជាវិជ្ជមាន (៣). ពណ៌នាពីនីតិវិធីសុវត្ថិភាពនានា និងវិធានការសម្រាលនានាសំរាប់សកម្មភាពនានាដែលអាចបង្កើត ឡើងជាមួយផលប៉ះពាល់សង្គម និងបរិស្ថាន និងទី (៤). ការសង្ខេបនូវការរៀបចំការតាមដាន និងស្ថាប័ន។ នីតិវិធីជាក់លាក់មួយចំនួន និងសេចក្តីណែនាំដើម្បីសម្រាលសក្តដានុពលនៃផលប៉ះពាល់បរិស្ថាននានាត្រូវបានដាក់ បញ្ចូលទៅក្នុងឧបសម្ពន្ធ័នៅក្នុងគម្រោងគ្រប់គ្រងសង្គម និងបរិស្ថាននេះ ខណៈដែលទិដ្ឋភាពសង្គមទាំងនោះពាក់ពន្ធ័ត្រូវបានតម្រូវដោយគោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច OP4.12) និងការមិនស្ម័គ្រចិត្តក្នុងការតាំងលំនៅដ្ឋានឡើងវិញ (OP4.10) ត្រូវបានរៀបចំជាឯកសារដោយខ្លួនឯង ដែលជាផ្នែកនៃគម្រោងគ្រប់គ្រងសង្គម និងបរិស្ថាននេះ (OP4.10)។

២. ផ្នែកនានាខាងក្រោមពិពណ៌នាយ៉ាងសង្ខេបនូវការលំអិតពីគម្រោង សង្កត់ធ្ងន់ទៅលើទាំងនោះដែលអាចជះឥទ្ធិពលអាក្រក់ដល់គោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោក (ផ្នែកទី ២) ដំណើការឆ្លុះបញ្ចាំងសុវត្ថិភាព (ផ្នែកទី ៣) និងការរៀបចំការអនុវត្ត (ផ្នែកទី ៤)។ ខណៈដែលសកម្មភាពវិនិយោគនានា (សមាសភាពទី ៣) ដែលត្រូវបានកំណត់មុនពេលនៃការវាយតម្លៃ ដែលអាចទទួលយកនូវវិធានការសម្រាលនានាដែលបានកំណត់នៅក្នុងជំហានទី ៤ សកម្មភាពថ្មីៗនានាត្រូវបានកំណត់ក្នុងកំលុងពេលនៃការអនុវត្តគម្រោង (សមាសភាពទី ៣-១ និង ៣-២) នឹងអនុវត្តចាប់តាំងពីជំហានទី ១ ទៅដល់ជំហានទី ៤ ដោយរួមបញ្ចូលទាំងការរក្សាទុកនូវឯកសារនៃលទ្ធផលនានា។

## II. សេចក្តីលំអិតគម្រោង

៣. គម្រោងមានគោលបំណងដើម្បីបង្កើតឡើងនូវគំរូសំខាន់ៗនៃគ្រប់គ្រងធនធានទឹកចម្រុះដែលអនុវត្តនៅតាមអាងទន្លេមេគង្គផ្នែកខាងក្រោមនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អនុ-ជាតិ (ខេត្ត)។ សកម្មភាពនានានឹងត្រូវបានអនុវត្តតាមរយៈសមាសភាពចំនួន ៣ ដូចខាងក្រោម:

- *សមាសភាពទី ១: ការគ្រប់គ្រងធនធានទឹកថ្នាក់តំបន់-* សមាសភាពនេះមានគោលបំណងដើម្បីបង្កើនជាសៀវភៅ កិច្ចសហប្រតិបត្តិការ និងការយោគយល់ស្តីពីគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះនានាក្នុងចំណោមបណ្តាប្រទេសដែលស្ថិតនៅតាមអាងទន្លេមេគង្គផ្នែកខាងក្រោម។ សកម្មភាពសំខាន់ៗនានាគួររួមបញ្ចូលជំនួយផ្នែកបច្ចេកទេស ការសាងសម្ថភាព ការប្រជុំ/សិក្ខាសាលា ទស្សនៈកិច្ចសិក្សា និងដែលមិនទំនងជាមិនមានផលប៉ះពាល់ទៅដល់គោលនយោបាយរបស់ធនាគារពិភពលោក។

- *សមាសភាពទី ២: ការគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ-* គោលបំណងសំខាន់ៗគឺដើម្បីគាំទ្រការគ្រប់គ្រងធនធានទឹកចម្រុះនៅក្នុងប្រទេសឡាវ ដែលមានបរិមាណជាង ៣០ ភាគរយនៃលំហូររបស់អាងទន្លេមេគង្គ។ សកម្មភាពសំខាន់ៗនឹងរួមបញ្ចូលជំនួយផ្នែកបច្ចេកទេស ការប្រជុំ សិក្ខាសាលា ទស្សនៈកិច្ចសិក្សា និងសកម្មភាពកសាងសមត្ថភាពផ្សេងៗទៀត ដូចជាឡាន និងសម្ភារៈមួយចំនួន និងការកសាងឡើងវិញនៃការិយាល័យ រឺសំណង់តូចៗ និងមិនទំនងជាមានផលប៉ះពាល់ទៅដល់គោលនយោបាយនានារបស់ធនាគារពិភពលោក។

- *សមាសភាពទី ៣: ការគ្រប់គ្រងធនធានវារីជាតិ និងព្រៃលិចទឹកនៅតាមតំបន់សំខាន់ៗថ្នាក់តំបន់-* សមាសភាពនេះមានគោលបំណងដើម្បីបង្ហាញនូវការអនុវត្តប្រកបដោយភាពជោគជ័យនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះដែមទាក់ទងទៅនឹង: (ក).ការគ្រប់គ្រងព្រៃលិចទឹកនៅតាមទីតាំងដែលបានជ្រើសរើសនៅក្នុងអាងទន្លេនៅក្នុងប្រទេសឡាវ និង (ខ). កិច្ចអភិវឌ្ឍន៍ការគ្រប់គ្រងជលផលតំបន់រួមគ្នានៅតាមទីតាំងអាទិភាពនៃប្រទេសកម្ពុជា និងឡាវ។ សកម្មភាពនានានឹងត្រូវបានគេអនុវត្តតាមរយៈអនុសមាសភាពដូចខាងក្រោម:

  (៣.១). *ការគ្រប់គ្រងព្រៃលិចទឹក និងអាងទន្លេនៅតាមផ្នែកនៃ Xe Bang Fai (XBF) និង Xe Bang Hian (XBH) នៅក្នុងប្រទេសឡាវ សកម្មភាពសំខាន់ៗគួររួមបញ្ចូល:*

(៣.១.១). គាំទ្រកិច្ចអភិវឌ្ឍន៍នៃអង្គការអាងទន្លេ និងគម្រោងចំផែនការអាងទន្លេដោយផ្តោតទៅលើ " ទីតាំងសំខាន់ៗ " កិច្ចអភិវឌ្ឍន៍ផែនការគ្រប់គ្រងព្រៃលិចទឹកសំរាប់ផ្នែក XBF និង XBH ដោយផ្តោតទៅលើចំណុចរួមគ្នារវាងដែទន្លេមួយចំនួន និងទន្លេមេគង្គ។ គម្រោងគួរគាំទ្រជំនួយបច្ចេកទេស ការបណ្តុះបណ្តាល និងសម្ភារៈ និងការជួសជុលការិយាល័យ។

(៣.១.២). ការស្តាបនាឡើងវិញនូវទ្វារទឹកជំនន់ដែលមានស្រាប់ដើម្បីស្តារឡើងវិញលើការគ្រប់គ្រងព្រៃលិចទឹក និងការធ្វើបំលាស់ទីត្រី ១៤ ០០០ ហ.ត និងការស្តាបនាឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីគាំទ្រការស្តារឡើងវិញនៃការដាំដុះស្រូវនៅតាមតំបន់ព្រៃលិចទឹក និងការពងកូនរបស់ត្រីដែលមានទំហំ ៨ ៥០០ ហ.ត ជាមួយនឹងការផ្តល់នូវការគាំទ្រត្រូវបានបង្កើនឡើង ដែលមានទឹកគ្រប់គ្រាន់ប្រព័ន្ធក្នុងការបង្ករង្កើនផលស្រូវតាមរយៈការងារសង្គមស៊ីវិល គាំទ្រនូវសម្ភារៈ និងការផ្សព្វផ្សាយ និង

(៣.១.៣). ផ្តល់នូវការគាំទ្រទៅដល់រដ្ឋបាលថ្នាក់ខេត្តនៃរដ្ឋបាលបរិស្ថាន និងធនធានទឹក និងក្រសួងកសិកម្ម (ធារាសាស្ត្រ និងនាយកដ្ឋានជលផល) សំរាប់ការអនុវត្តអនុ-សមាសភាព។

(៣.២). *គាំទ្រដើម្បីលើកកម្ពស់ក្នុងការគ្រប់គ្រងធនធានវារីជាតិនៅក្នុងប្រទេសឡាវ និងកម្ពុជា* ការបង្ហាញនូវតំបន់ពងកូនសំខាន់ៗនៅក្នុងទន្លេមេគង្គ និងសកម្មភាពសំខាន់ៗដែលគួរបញ្ចូលៈ

(៣.២.១). គាំអង្គការទ្រសហគមន៍តាមរយៈការគ្រប់គ្រងដោយសហគមន៍ជលផលនៅក្នុងខេត្ត ចំប៉ាសាក់ អាតាប៉ឺ សេកុង (ប្រទេសឡាវ) និងខេត្តស្ទឹងត្រែង និងក្រចេះ (ប្រទេសកម្ពុជា) ដោយរួមទាំងកិច្ចអភិរក្ស និងអភិវឌ្ឍន៍ ការអនុវត្ត និងអភិវឌ្ឍន៍នៃសកម្មភាពសាកល្បងចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ (ឧ. ការចិញ្ចឹមសត្វ និងវារីវប្បកម្ម) និងផែនសកម្មភាពអភិវឌ្ឍន៍ឃុំរួមទាំងការគាំទ្រទៅដល់ហេដ្ឋារចនាសម្ពន្ធ័។ គម្រោងគួរផ្តល់វគ្គបណ្តុះបណ្តាល ការបង្កើតនៃយន្តការសារទុក្ខ ការទៅដល់សហគមន៍ តម្លៃការប្រតិបត្តិ ទំនីញ និងការងារសង្គមស៊ីវិល។

(៣.២.២). ពង្រឹងការគ្រប់គ្រងវិស័យជលផលសារធារណៈសំរាប់ស្ថាប័នថ្នាក់ស្រុក និងថ្នាក់ខេត្ត (ក). ការប្រមូលទិន្នន័យផលចាប់ត្រី បទបញ្ញា និងការតាមដាន រួមទាំងស្ថាប័នសហគមន៍ជលផល (ខ). សកម្មភាពផ្សព្វផ្សាយ និង (គ). គាំទ្រដល់ការធ្វើវារីវប្បកម្មនៃប្រភេទត្រីក្នុងស្រុក និងស្តុកតាមរយៈ

ការស្តារឡើងវិញនៃស្ថានីយ៍ភ្ញាស់កូនត្រី ជំនួយផ្នែកបច្ចេកទេស និងកផ្តល់ទស្សនៈកិច្ចសិក្សាដល់កសិករ។ គម្រោងគួរផ្តល់ហិរញ្ញវត្ថុ ការងារ វត្ថុបណ្តុះបណ្តាល និងតម្លៃនៃការអនុវត្ត និង

(៣.២.៣). ផ្តល់នូវការគាំទ្រដល់ការគ្រប់គ្រងសមាសភាពនៃនាយកដ្ឋានជលផលនៅក្នុងខេត្ត ប៉ាកសេ ចំប៉ាសាក់ (ប្រទេសឡាវ) និងទីក្រុងភ្នំពេញ (កម្ពុជា) រួមទាំងតម្លៃប្រតិបត្តិ និងការជួសជុលការិយាល័យដែលមានតម្លៃតិចតួច។

៤. គម្រោងគ្រប់គ្រងធនធានទឹកចម្រុះគឺជាគម្រោងថ្នាក់តំបន់ដែលនឹងត្រូវបានអនុវត្តរយៈពេល ៦ ឆ្នាំ (២០១១-២០១៦)។ គណៈកម្មការទន្លេមេគង្គ (MRC) តាមរយៈលេខាធិការដ្ឋានរបស់វា នឹងជាភ្នាក់ងារអនុវត្តសំរាប់សមាសភាពទី ១ ខណៈដែលភ្នាក់ងារនានានៅក្នុងប្រទេសឡាវស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋបាលបរិស្ថាន និងធនធានទឹក (WREA) នឹងជាភ្នាក់ងារអនុវត្តសំរាប់សមាសភាពទី ២ និងអនុសមាសភាព ៣-១។ នាយកដ្ឋានបសុព្យាបាល (DLF) នៃក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ (MAF) និងការិយាល័យរបស់វានានានៅថ្នាកលខេត្ត ចំប៉ាសាក់ សេកុង និង អាតាតបឺ គឺជាភ្នាក់ងារអនុវត្តសំរាប់អនុសមាសភាព ៣-២ សំរាប់សកម្មភាពនានានៅក្នុងប្រទេសឡាវ។ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងជលផល (MAFF) គឺជាភ្នាក់ងារអនុវត្តសំរាប់សកម្មភាពនានានៅកម្ពុជាដែលស្ថិតនៅក្រោមអនុសមាសភាព ៣-២។ នៅក្នុងបរិបទនេះគម្រោងគ្រប់គ្រងសង្គម និងបរិស្ថាននឹងអនុវត្តតែនៅកម្ពុជាសំរាប់សកម្មភាពនានាត្រូវបានអនុវត្តនៅក្រោមអនុសមាភាព ៣-២។

## III. វិធានការសម្រាល និងបញ្ហាសុវត្ថិភាពសំខាន់ៗ

៥. ធនាគារពិភពលោកបានចាត់ថ្នាក់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះជា "ផ្នែក ខ" គម្រោង និងស្ថិតនៅក្រោគោលនយោបាយ គោលនយោបាយចំនួន ៦ត្រូវបានមានផលប៉ះពាល់: ការវាយតម្លៃបរិស្ថាន *(OP 4.01)* ការគ្រប់គ្រងសត្វចង្រៃ *(OP 4.09)* ជនជាតិដើមភាគតិច *(OP 4.10)* ការតាំងលំនៅដ្ឋានដោយមិនស្ម័គ្រចិត្ត *(OP 4.12)* ន ជម្រកធម្មជាតិ *(OP 4.04)* និងផ្លូវទឹកអន្តរជាតិ។ ព្រំដែន និងគោលបំណងរបស់គម្រោងដែលបានផ្តល់អោយ វាត្រូវបានគេប្រមើលទុកជាមុនថា សកម្មភាពគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនឹងមិនបណ្តាលអោយមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងផលប៉ះពាល់ដល់សង្គម។ គារវាយតម្លៃផលប៉ះពាល់តំបូងត្រូវបានអនុវត្តសំរាប់សកម្មភាពនានាដែលអាចត្រូវបានកំណត់មុនពេលនៃការវាយតម្លៃ ដែលគាំទ្រនូវការសន្និដ្ឋាន។ ខាងក្រោមសង្ខេបនូវបញ្ហាសំខាន់ៗ និងសកម្មភាពនានាត្រូវបានអនុវត្តក្នុងកំលុងពេលនៃការអនុវត្តនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ

៦. ***ផលប៉ះពាល់ដោយសារការងារសង្គម:*** រាល់សកម្មភាពវិនិយោគ/អនុគម្រោងដែលទាក់ទងនឹងការងារសាងសង់ រឺការផ្លាស់ប្តូរនៃការប្រើប្រាស់ដី រឺទឹកមានសក្តដានុពលដើម្បីជំរុញផលប៉ះពាល់បរិស្ថានជាអវិជ្ជមាន។ សកម្មភាពគម្រោងដែលបានកំណត់ដោយការវាយតម្លៃ ដែលបានស្នើសុំថាសកម្មភាពនានាដែលទាក់ទងទៅនឹងការងារសសង្គមនានាគួរត្រូវបានកំណត់លើការសាងសង់នៃសំណង់តូចៗ (សមាសភាពទី ២) និងការស្តារឡើងវិញ/ការស្ថាបនានៃទ្វារទឹកជំនន់ ហេដ្ឋារចនាសម្ព័ន្ធនៅតាមភូមិដូចជាផ្លូវលំ ការផ្គត់ផ្គង់ទឹក ស្ថានីយ៍ភ្ញាស់កូនត្រី...។ល។ (សមាសភាពទ ៣)។ ផលប៉ះពាល់ជាអវិជ្ជនានាដោយសារសកម្មភាពសាងសង់ជាលក្ខណៈគ្រួសារនឹងត្រូវបានកាត់បន្ថយតាមរយៈការពិនិត្យទៅលើការអនុវត្តវិស្វកម្មដែកមានលក្ខណៈល្អប្រសើរ/ គេហកិច្ចដែលអាចកាត់បន្ថយនូវធូលី សំលេង និងកាកសំណល់ ក៏ដូចជាការរក្សាទុកក្បែរៗសហគមន៍ដែលបានប្រាប់។ ការសាងសង់ថ្នាក់មធ្យម រឺសកម្មភាពផ្សេងៗទៀតត្រូវបានសង្ឃឹមថាផលិតយ៉ាងត្រឹមត្រូវ ផលប៉ះពាល់បរិស្ថាននៅតាមមូលដ្ឋាន ដែលអាចត្រូវបានកំណត់ក្នុងកំលុងពេលនៃការអនុវត្តគម្រោងនឹងអនុវត្តតាមទីតិវិធីឆ្លុះបញ្ចាំងសុវត្ថិភាពដែលបានពណ៌នានៅក្នុងផ្នែកទី ៤ ខាងក្រោម។ ប្រសិនបើការពិនិត្យបរិស្ថានតំបូងត្រូវបានតម្រូវដោយច្បាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) របស់រដ្ឋាភិបាល គម្រោងនឹងរៀបចំឯកសារសមស្រប និងដាក់ស្នើដល់ការអនុមត័របស់រដ្ឋាភិបាល។ សកម្មភាពដែលមានទំហំធំដែលតម្រូវអោយមានការវាយតម្លៃពីផលប៉ះពាល់បរិស្ថាន (EIA) ដោយច្បាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន នឹងមិនត្រូវបានអនុញ្ញាតិ និងទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុង " បញ្ជីនៃផលប៉ះពាល់ " (ឧបសម្ព័ន្ធ ១) ។ លក្ខខ័ណ្ឌជាក់លាក់នានាគួរត្រូវបានរួមបញ្ចូលទាំងការឯកសារដេញថ្លៃសំរាប់រាល់ប្រភេទការងារសង្គមស៊ីវិលនឹងត្រូវបានផ្តល់អោយនៅលើវិធានប្រតិបត្តិសុវត្ថភាព

៧. ***យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ*** ព្រះរាជាណាចក្រកម្ពុជាបានមានបទពិសោធន៏ចំពោះការទំលាក់គ្រាប់បែកយ៉ាងធ្ងន់ធ្ងរក្នុងកំលុងពេលនៃសង្គ្រាមឥណ្ឌូចិន ក៏ដូចជាការប្រើប្រាស់យុទ្ធភ័ណ្ឌធំៗក្នុងកំលុងពេលជំលោះផ្ទៃក្នុងដែលនាំអោយមានភាពប្រថុយប្រថានផ្នែកសុវត្ថិភាពនៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO)។ យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគឺជាឧបសគ្គដ៏សំខាន់ដល់ការអភិវឌ្ឍន៍កសិកម្ម និងការប្រើប្រាស់ដី។ ដូចជាផ្នែកនៃដំណើការពិគ្រោះយោបល់ទូទៅ និងដំណើការឆ្លុះបញ្ចាំងតំបូង ការវាយតម្លៃរហ័សមួយនឹងត្រូវបានធ្វើឡើងជាមួយសហគមន៍ដើម្បីកំណត់នូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលអាចមាន ទីតាំងរបស់វា និងសក្តដានុពលគ្រោះថ្នាក់។ ប្រសិនបើភាពគ្រោះថ្នាក់នៅមានមន្រ្តីគម្រោង នឹងទាក់ទងជាមួយភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវសំរាប់ការបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងស្នើសុំជំនួយនៅក្នុងការអភិវឌ្ឍន៍នូវគម្រោងសាមញ្ញមួយដើម្បីសំអាតនូវយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ បន្ទាប់ពីសំអាតជាក់ស្តែង គម្រោងនឹងផ្តល់ការគាំទ្រសំរាប់សកម្មភាពដែលបានស្នើ។

៨. ***ការគ្រប់គ្រងសត្វចង្រៃ:*** ការអនុវត្តនៃអនុសមាសភាព ៣-២ សំរាប់សកម្មភាពនៅកម្ពុជាអាចទាក់ទងទៅនឹងការអភិវឌ្ឍន៏គម្រោងធារាសាស្ត្រខ្នាតតូចនៅតាមសហគមន៏ ដែលត្រូវបានគេជ្រើសរើសដូចជាជម្រើសនៃមុខរបរ ដើម្បីសម្រាលនូវផលប៉ះពាល់ជាអវិជ្ជមាននានាដោយសារធនធានមានកម្រិត ដូចដែលត្រូវបានកំណត់ដោយគោលនយោបាយធនាគារ ពិភពលោក និងមិនទំនងជាបង្កើននូវការប្រើប្រាស់ថ្នាំសំលាប់សត្វចង្រៃ និងជី។ ទោះជាយ៉ាងណា ដើម្បីសម្រាលនូវសក្តដានុពលផលប៉ះពាល់នេះ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះនឹងហាមឃាត់នូវការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតដែលមានទ្រង់ទ្រាយធំ " *បញ្ជីនៃផលប៉ះពាល់* " និងផ្តល់នូវវគ្គបណ្តុះបណ្តាលទៅដល់មន្ត្រី និងកសិករសំខាន់ៗស្តីពីការគ្រប់គ្រងសត្វចង្រៃចម្រុះ និងសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត នេះជាការដាក់បញ្ចូលទៅក្នុងផ្នែកមួយវគ្គបណ្តុះបណ្តាលពីសុវត្ថិភាព។ វិធានការនេះត្រូវបានគេចាត់ទុកថាមានលក្ខណះសមស្របសំរាប់អនុសមាសភាពនៅកម្ពុជា។

***៩. ជម្រកសុវត្ថិភាពសំខាន់*** ការអនុវត្តនៃអនុសមាសភាព ៣-២ សំរាប់នៅកម្ពុជានឹងទាក់ទងផងដែរទៅនឹងតំបន់រំាសារដែលស្ថិតនៅតាមព្រំដែននៃប្រទេសឡាវ និងកម្ពុជា។ ទោះបីជាផលប៉ះពាល់ជាទូទៅទាំងមូលត្រូវបានគេជឿជាក់ថាមានផលជាវិជ្ជមាន ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវបានផ្តល់ដើម្បីធានាថាសកម្មភាពនានានៅក្នុង រឺក្បែរតំបន់រំាសារនឹងត្រូវបានយកចិត្តទុកដាក់ និងមានភាពស្របទៅនឹងគម្រោងគ្រប់គ្រងនៃទីតាំងនានា និងសហការណ៏យ៉ាងជិតជាមួយភ្នាក់ងារទទួលខុសត្រូវសំរាប់ការគ្រប់គ្រងតំបន់រំាសារ។ ផ្នែកអនុវត្តនឹងធ្វើការយ៉ាងជិតស្និតជាមួយភ្នាក់ងារទទួលខុសត្រូវសំរាប់ការគ្រប់គ្រងតំបន់រំាសារដើម្បីពង្រឹងនូវកំលាំង និងកិច្ចខិតខំអោយស្របតាមគោលការណ៏ដែលបានសង្ខេបនៅក្នុងគោលនយោបាយធនាគារពិភពលោក និងវិធាននានាស្តីពីជម្រកសុវត្ថិភាពធម្មជាតិនានា (OP 4.04) ។ ដំណើរការច្បាស់លាស់សំរាប់ការអនុវត្ត និងរៀបចំផែនការនៅតាមតំបន់រំាសារនឹងត្រូវបានអភិវឌ្ឍន៏ដែលជាផ្នែកមួយនៃវិធានប្រតិបត្តិសុវត្ថិភាព។

១០. ***ជនជាតិដើមភាគតិច:*** ការអនុវត្តនៃអនុសមាសភាព ៣-២ នឹងទាក់ទងជាមួយជនជាតិដើមភាគតិច។ គម្រោងនឹងអនុវត្តតាមគោលការណ៏សំខាន់ៗរបស់គោលនយោបាយធនាគារពិភពលោក ពាក់ព័ន្ធនឹងជនជាតិដើមភាគតិច (OP/BP 4.10) ដែលធានាថា ក). ដំណើរការពិគ្រោះយោបល់ធ្វើឡើងដោយសេរី មុន និងកិច្ចពិគ្រោះយោបល់ត្រូវបានប្រាប់ទៅដល់" ការគាំទ្រដល់សហគមន៏ទាំងមូល" ខ)." ធានាថាជនជាតិដើមភាគតិចមិនទទួលរងនូវការឈឺចាប់ក្នុងកំលុងពេលនៃ ដំណើការអភិវឌ្ឍន៏ " និង គ). ដែលពួកគេទទួលបាននូវ "ផលប្រយោជន៏សេដ្ឋកិច្ច និងការស្រុះស្រួលសង្គមផ្នែកខាង ប្រពៃណី "។ ជនជាតិដើមភាគតិច ដូចដែលបានប្រើសំរាប់

គម្រោងគ្រប់គ្រងធនធានទឹកចម្រុះសំរាប់នៅកម្ពុជា រួមទាំងជនជាតិដើមដែលកំពុងរស់នៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង ដែលអាចរួមបញ្ចូលទាំង ជនជាតិខ្មែរ ឡាវ កាវ៉ែត គួយ វៀតណាម ចិន ភ្នង ឡន់ ប្រាវ ក្រឹង ចាម ទំពួន កាចក និងចារ៉ាយ។ គម្រោងអភិវឌ្ឍន៍ជនជាតិដើម ភាគតិចត្រូវបានរៀបចំជាឯកសារដើម្បីផ្ដល់នូវសេចក្ដីណែនាំស្ដីពីការពិគ្រោះយោបល់ និងវិធានការសម្រាលនៅពេលផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចនឹងត្រូវបានរៀបចំ និងដាក់ស្នើទៅធនាគារពិភពលោក។

១១. ***ការទទួលបាននូវដី:*** គម្រោងនឹងមិនជាប់ពាក់ព័ន្ធការតាំងលំនៅដ្ឋានឡើងវិញ រឺផ្ដល់នូវដីដែលមានទំហំធំៗ ប៉ុន្តែអាចផ្ដល់ទំហំដីតូចៗសំរាប់ហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៍ និងសហគមន៍ជលផល។ ការតាំងលំនៅដ្ឋានឡើងវិញ និងការកំទេចចោលលំនៅដ្ឋាន និងជំនួញនឹងមិនត្រូវបានអនុញ្ញាត និងត្រូវបានដាក់បញ្ចូលនៅក្នុង " *បញ្ជីនៃផលប៉ះពាល់ជាអវិជ្ជមាន* "។ គម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ត្រូវបានរៀបចំជាឯកសារ និងវានឹងត្រូវបានគេអនុវត្តទៅក្នុងអនុសមាសភាព ៣-២ ខណៈដែលការផ្ដល់ដីត្រូវបានជាប់ពាក់ព័ន្ធ។ គម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) កំណត់នូវនិយមន័យនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ (PAPs) លើកទឹកចិត្ត និងផ្ដល់សិទ្ធិ មាតិកានៃផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញ (RAP) និងដំណើការនៃកិច្ចពិគ្រោះយោបល់ រួមទាំងនីតិវិធីនៃការសារទុក្ខ និងភាពតម្រូវការនៃការតាមដាន។ ការផ្ដល់ដីដោយស្ម័គ្រចិត្តនឹងត្រូវបានអនុញ្ញាតិតែមួយគត់ខណៈដែលវាមាននៅក្នុងការពិពណ៌នាដោយលំអិតនៅក្នុងគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ។

១២. ***ធនធានដែលប្រើប្រាស់ដោយការកំណត់:*** ការអនុវត្តនៃការគ្រប់គ្រងវិស័យជលផល (អនុសមាសភាព ៣-២) អាចប្រើប្រាស់ដោយកំណត់ទៅលើធនធាន កិច្ចខិតខំប្រឹងប្រែងគួរអោយកត់សំគាល់ដើម្បីពង្រឹងច្បាប់ជាតិរឺច្បាប់នៅតាមមូលដ្ឋានដើម្បីការពារ និងអភិរក្សតំបន់នានា។ ភាពពាក់ព័ន្ធនេះត្រូវបានគេចាត់ទុកក្នុងកំលុងពេលនៃការរៀបចំគម្រោង និងការផ្ដល់ នៃសកម្មភាពសាកល្បងចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារដែលត្រូវបានគេដាក់បញ្ចូលនៅក្នុងអនុសមាសភាពទី ៣-២។ ក្នុងកំលុងពេលនៃការវាយតម្លៃតំបូង និងការខិតជិតមកដល់ត្រូវបានទទួលយក ក្នុងគោលការណ៍ តាមរយៈ សហគមន៍ និងអជ្ញាធរមូលដ្ឋានក៏ដូចជាអង្គការនៅក្នុងស្រុក និងអន្តរជាតិនានានៅក្នុងតំបន់របស់គម្រោង:

- ទី ១ ការគ្រប់គ្រងជលផលដែលប្រសើរគួរផ្ដល់ផលប្រយោជន៍ទៅដល់សហគមន៍មូលដ្ឋានរយៈពេលយូរ តាមរយៈ ការបង្កើតនូវការគ្រប់គ្រងវិស័យជលផលប្រកបដោយនិរន្តរភាព។

- ទី ២ ផែនការគ្រប់គ្រងវិស័យជលផលគួរត្រូវបានអភិវឌ្ឍន៏តាមរយៈភាពជាម្ចាស់ និងការចូលរួមយ៉ាងទូលំទូលាយរបស់សហគមន៏ និង
- ទី ៣ គម្រោងក៏ផ្តល់ដល់តំបន់នៅជុំវិញនូវជម្រើសមុខរបរចិញ្ចឹមជីវិតផងដែរ (ដែលនឹងត្រូវបានជ្រើសរើសតាមរយៈការរៀបចំផែនការដោយមានការចូលរួមជាមួយប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់) ដើម្បីសម្រាលនូវសក្តានុពលនៃផលប៉ះពាល់ជាអវិជ្ជមាន។

១៣. ភ្នាក់ងារអនុវត្តនានានៃអនុសមាសភាពនេះនឹងបញ្ចប់នូវសកម្មភាព និងរក្សានូវឯកសារសមស្របមួយ និងបំពេញ។ ប្រសិនបើប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាជនជាតិភាគតិចដូចដែលបានកំណត់ដោយគោលនយោបាយធនាគារពិភពលោក OP 4.10 កិច្ចពិគ្រោះយោបល់នឹងអនុវត្តតាមគោលការណ៍ និងដំណើការដែលបានរៀបរាប់នៅក្នុងគម្រោងអភិវឌ្ឍន៏ជនជាតដើមភាគតិច និងឯកសារត្រឹមត្រូវ និងការបំពេញនឹងត្រូវបានតម្រូវ។ ការប្រុងប្រយ័ត្នជាពិសេសនឹងត្រូវបានផ្តល់អោយដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានទៅលើស្ត្រី និងក្រុមមនុស្សដែលមិនទទួលបាននូវផលប្រយោជន៏។

១៤. ***យេនឌ័រ:*** ក្នុងកំលុងពេលនៃការរៀបចំនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ការប្រុងប្រយ័ត្នត្រូវបានផ្តល់ដើម្បីលើកទឹកចិត្តស្ត្រីដើម្បីដើរតួយ៉ាងសកម្មនៅក្នុងសំណើការនៃកិច្ចពិគ្រោះយោបល់។ ក្នុងកំលុងពេលនៃកិច្ចប្រឹងប្រែងនៃការអនុវត្តនឹងត្រូវបានបន្តដើម្បីប្រាកដថាស្ត្រីគឺ (ក). ត្រូវបានពិគ្រោះយោបល់ និងភាពពាក់ព័ន្ធរបស់ពួកគេនឹងត្រូវលើកឡើង (ខ). ត្រូវបានពិគ្រោះ និងបណ្តុះបណ្តាលស្តីពីការជ្រើសរើសមុខរបររស់នៅដែលអាចអោយពួកគេស្តារឡើងវិញនូវប្រាក់ចំណូល និងពង្រឹងនូវកម្រិតជីវភាពរស់នៅរបស់ពួកគេ (គ). ត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញនូវការជួនប្រជុំជាក្រុមនៅតាមសហគមន៏ ការពិភាក្សាជាក្រុម ការអនុវត្ត និងការរៀបចំផែនការ និង (ឃ). ត្រូវបានតំណាងស្មើភាពគ្នានៅក្នុងគណៈកម្មាការជួសជុលឡើងវិញ និងសារទុក្ខ។

១៥. ***សកម្មភាពដែលមិនបានកំណត់នានា:*** មានសកម្មភាពជាច្រើនដែលមិនអាចត្រូវបានកំណត់មុនពេលនៃការវាយតម្លៃ។ ដើម្បីជៀសវាង រឺសម្រាលនូវភាពគ្រោះថ្នាក់ទាំងនេះ ដំណើរការឆ្លុះបញ្ចាំងពីសុវត្ថិភាពដែលមាន " បញ្ជីនៃផលប៉ះពាល់ " ជាការវាយតម្លៃដែលមានលក្ខណៈសាមញ្ញ និងសកម្មភាពជាក់លាក់ត្រូវបានផ្តល់ដើម្បីធានាថាបញ្ហាជាអវិជ្ជមាននានាត្រូវបានកំណត់ និងវិធានការនៃការសម្រួលគ្រប់គ្រាន់ត្រូវបានអនុវត្ត។ ទាំងនេះដើម្បីធានាថាសកម្មភាពគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គស្របទៅតាមច្បាប់របស់រាជរដ្ឋាភិបាល និងគោលនយោបាយរបស់ធនាគារពិភពលោក និងប្រសិនបើបង្កើនការទទួលបាននូវផលជាវិជ្ជមាន។

## IV. ដំណើការត្រួតពិនិត្យ ផ្ទះបញ្ចាំងសុវត្ថិភាព

១៦. ការវាយតម្លៃ និងឆ្លុះបញ្ចាំងសុវត្ថិភាពត្រូវបានធ្វើឡើងសំរាប់សកម្មភាពនានាដែលបានកំណត់មុនពេលនៃការវាយតម្លៃ និងវិធានការសម្រាលនានាដែលបានតម្រូវ ត្រូវបានកំណត់ និងពួកវាត្រូវបានតាមដាន និងប្រតិបត្តិក្នុងកំលុងពេលនៃការអនុវត្ត។ រាល់សកម្មភាពត្រូវបានកំណត់ក្នុងកំលុងពេលនៃការអនុវត្តនឹងធ្វើការឆ្លុះបញ្ចាំងសុវត្ថិភាពជាមុនចំពោះការអនុវត្ត និងការអនុម័តរបស់ពួកគេ។ នីតិវិធីនៃការឆ្លុះបញ្ចាំងនឹងកំណត់ (១). ប្រសិនបើសកម្មភាពដែលបានស្នើសុំគឺលើកទឹកចិត្តសំរាប់ថវិការបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (២). ប្រសិនបើ និងអ្វីដែលជាបញ្ហាសុវត្ថិភាពចាំបាច់បានត្រូវបង្ហាញ និង (៣). តើឯកសារសុវត្ថិភាពអ្វីខ្លះចាំបាច់ត្រូវបានរៀបចំ។ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គនឹងថែរក្សានូវកំណត់ត្រានូវរាល់ការវាយតម្លៃដែលបានទទួល និងការសម្រេចចិត្តនៃការឆ្លុះបញ្ចាំងសំរាប់សេចក្តីសង្ខបរបស់ធនាគាពិភពលោក។ ខាងក្រោមជាសេចក្តីសង្ខេបជំហានសំខាន់ៗចំនួន ៤នៅក្នុងដំណើការវាយតម្លៃ និងឆ្លុះបញ្ចាំងនូវសុវត្ថិភាព:

### *ជំហានទី ១: ការឆ្លុះបញ្ចាំងនៃការលើកទឹកចិត្ត*

១៧. គម្រោងនឹងអនុវត្ត " បញ្ជីនៃផលប៉ះពាល់ " ជាមួយនឹងចំនួននៃសកម្មភាពដែលមិនលើកទឹកចិត្តដើម្បីជៀសវាងនូវផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងសង្គម ដែលមិនអាចត្រូវបានសម្រាលអោយបានសមស្របវី មិនបានលើកទឹកចិត្តសំរាប់ហិរញ្ញវត្ថុរបស់ធនាគារពិភពលោក។ បញ្ជីផលប៉ះពាល់ជាអវិជ្ជមានរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គត្រូវបានផ្តល់នៅក្នុងតារាងឧបសម្ព័ន្ធ ទី ១ នឹងត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីសុវត្ថិភាពសំរាប់រាល់សកម្មភាពនានារបស់គម្រោងដែលបានដាក់ស្នើ។ ពិគ្រោះយោបល់យ៉ាងជិតស្និតជាមួយអ្នកជំនាញការសុវត្ថិភាពរបស់ធនាគារពិភពលោកអាចជាការចាំបាច់។

### *ជំហានទី ២: ការឆ្លុះបញ្ចាំងសុវត្ថិភាពបច្ចេកទេស*

១៨. សំរាប់សកម្មភាពមួយចំនួនដែលមិនមាននៅក្នុង " បញ្ជីនៃផលប៉ះពាល់ " ដំណើការនៃការឆ្លុះបញ្ចាំងបច្ចេកទេសនឹងត្រូវបានយកមកអនុវត្តដើម្បីកំណត់នូវបញ្ហាសុវត្ថិភាពបរិស្ថាន និងសង្គមដែលអាចមាន។ គម្រោងគោលនយោបាយចំនួន ២ ទាក់ទងទៅនឹងក្រុមជនជាតិភាគតិច និងការផ្តល់នូវសំណង និងការតាំងលំនៅដ្ឋានឡើងវិញត្រូវបានរៀបចំ ខណៈដែលផ្នែកសុវត្ថិភាព នឹងវនឹងត្រូវបានដាក់បញ្ចូលទៅក្នុងវិធានការ ប្រតិបត្តិគម្រោង។ តារាងនៃការឆ្លុះបញ្ចាំងសង្គម និងបរិស្ថាននឹងត្រូវបានផ្តល់អោយនៅក្នុងវិធាន (សៀវភៅ ណែនាំ)

ហើយអាចអោយមន្ត្រី គម្រោងអាចកំណត់នូវបញ្ហាសុវត្ថិភាពនានាដែលអាចមាន និងបន្ទាប់មកធ្វើការសម្រេចចិត្តចំពោះឯកសារសុវត្ថិភាពត្រូវបានរៀបចំ។ គួរមានសារៈសំខាន់ចំពោះការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការក្រៅរដ្ឋាបាលក្នុងស្រុក និងអន្តរជាតិមួយចំនួន។ កិច្ចខិតខំនានាគួរត្រូវបានធ្វើឡើងដើម្បីពង្រឹងនូវផលប្រយោជន៍ និងកំលាំងបរិស្ថានស្របទៅតាមសកម្មភាពនានារបស់គណៈកម្មការទន្លេមេគង្គ និងបញ្ហានានា នៅតាមតំបន់មេគង្គខាងលើទៅក្នុងសកម្មភាពនានារបស់គម្រោង។ ***តារាងទី ១*** ពិពណ៌នានូវសកម្មភាព និងគន្លឹះសំខាន់ៗ ត្រូវបានអនុវត្តក្នុងកំលុងនៃដំណើការឆ្លុះបញ្ចាំងបច្ចេកទេស។ លទ្ធផលនៃការឆ្លុះបញ្ចាំងគួរត្រូវបានភ្ជាប់ទៅនឹងសកម្មភាពដែលបានដាក់ស្នើ/អនុគម្រោងក្នុងកំលុងពេលនៃដំណើការព្រមព្រៀង។ ប្រសិនបើមានបញ្ហាសំខាន់ៗត្រូវបានស្មានទុកមុនដោយធ្វើកិច្ចពិគ្រោះយោបល់ជាមួយធនាគារពិភពលោកនោះវានឹងមានភាពចាំបាច់។

១៩. ប្រសិនបើសកម្មភាពនានារបស់គម្រោងទាក់ទងទៅនឹងការងារសង្គមស៊ីវិលតូចៗ និងមិនតម្រូវការអនុម័តដោយរាជរដ្ឋាភិបាលសំរាប់ឯកសារផ្សេងៗទៀត ការអនុវត្តវិស្វកម្មដែលប្រសើរ (ឧបសម្ព័ន្ធទី ២) នឹងត្រូវបានអនុវត្ត និងតម្រូវការដាក់លាក់នានា រួមទាំងអនុប្រយោគ " ការរកឃើញដោយចៃដន្យ " នឹងត្រូវបានរួមបញ្ចូលនៅក្នុងឯកសារកិច្ចសន្យា និងការដេញថ្លៃ និងលទ្ធផលនៃការតាមដាននានា និងការបង្ហាញនៃម្ចាស់កិច្ចសន្យានឹងត្រូវបានរួមបញ្ចូលនៅក្នុងរបាយការណ៍វឌ្ឍនភាពរបស់គម្រោង។

២០. ប្រសិនបើសកម្មភាពដែលបានដាក់ស្នើ/តំបន់នានាដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិច គោលបំណង នីតិវិធី និងសំណើការ រួមទាំងនៅក្នុងរបាយការណ៍វឌ្ឍនភាព។ ប្រសិនបើមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជនជាតិដើមភាគតិចត្រូវបានស្មានទុកជាមុន ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) នឹងត្រូវបានរៀបចំដែលគួរតម្រូវពាយសេចក្តីសង្ខេបពីធនាគារពិភពលោក។

## ជំហានទី ៣: ការរៀបចំឯកសារសុវត្ថិភាព និងការជំរះ

២១. ប្រសិនបើសកម្មភាព/អនុគម្រោងនានាតម្រូវអោយរាជរដ្ឋាភិបាលអនុវត្តដោយយោងទៅតាមច្បាប់នៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន និង/រឺច្បាប់ផ្សេងៗទៀត មន្ត្រីគម្រោងនឹងពិគ្រោះយោបល់ជាមួយភ្នាក់ងារនានាស្តីពីការរៀបចំនានាសំរាប់ការចូលរួមនៃបញ្ហាសុវត្ថិភាពដែលបានកំណត់នានា និងការរៀបចំឯកសារ និងបង្ហាញ

ដល់ធនាគារពិភពលោក។ គម្រោងនឹងអនុវត្តតាមច្បាប់នានារបស់រាជរដ្ឋាភិបាល និងជួយនូវការជំរះ និងអនុម័តរបស់រាជរដ្ឋាភិបាលក្នុងខណៈដែលធ្វើការបង្ហាញទៅដល់ធនាគារ។

២២. វាជាសកម្មភាពដែលបានស្នើ/អនុគម្រោងដែលបានពាក់ព័ន្ធនឹងការផ្តល់ដី ការផ្តល់សំណង និង/រឺធនធាននានាដែលប្រើយ៉ាងកំណត់ នីតិវិធី និងគោលនយោបាយដែលបានរៀបរាប់នៅក្នុងគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញនឹងត្រូវបានអនុវត្តតាម ដោយរួមទាំងការរាយការណ៍ និងកត់ត្រាយ៉ាងត្រឹមត្រូវ។

**ជំហានទី ៤: ការអនុវត្តសុវត្ថិភាព ការគ្រប់គ្រង ការតាមដាន និងការរាយការណ៍**

២៣. ក្នុងកំលុងពេលនៃការអនុវត្ត ផ្នែកអនុវត្តគម្រោងនានា (PIUs) ដែលទទួលខុសត្រូវអនុសមាសភាពនីមួយៗ នឹងទទួលខុសត្រូវដើម្បីធានានូវការអនុវត្តប្រកបដោយសុវត្ថិភាពនៃវិធានការសុវត្ថិភាព ដោយពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ និងសហគមន៍មូលដ្ឋាននានា។ ការផ្តល់នូវការបណ្តុះបណ្តាលសុវត្ថិភាពគួរជាការចាំបាច់ដើម្បីធានាការយល់ដឹងជាក់លាក់នៃវិធានការសុវត្ថិភាព និងបង្កើនឡើងនូវប្រសិទ្ធិភាពរបស់ពួកគេ។ ផ្នែកគ្រប់គ្រងគម្រោង និង/រឺភ្នាក់ងារអនុវត្តជាតិនឹងគ្រប់គ្រងយ៉ាងទៀងទាត់ និងតាមដានការបង្ហាញនូវការអនុវត្តសុវត្ថិភាព និងរួមទាំងវឌ្ឍនភាព/លទ្ធផលនៅក្នុងរបាយការណ៍វឌ្ឍនភាពគម្រោង។ ព័ត៌មានទាក់ទងទៅនឹងនីតិវិធីសុវត្ថិភាព និងការបង្ហាញគួរត្រូវបានបិទផ្សាយយ៉ាងកំណត់ទៅដលសាធារណៈ។ ធនាគារពិភពលោកនឹងអនុវត្តការគ្រប់គ្រងសុវត្ថិភាព តាមដាន និងសង្ខេប។

## V. ការអនុវត្ត និងការរៀបចំការតាមដាន

២៤. ភាពទទួលខុសត្រូវទូទៅដែលស្របទៅតាមគម្រោងគ្រប់គ្រងសង្គម និងបរិស្ថានត្រូវបានចែករំលែករវាងផ្នែកអនុវត្តគម្រោងដែលទទួលខុសត្រូវសំរាប់ការអនុវត្តនៅថ្នាក់អនុសមាសភាព និងផ្នែកគ្រប់គ្រងគម្រោងដែលទទួលខុសត្រូវសំរាប់ការគ្រប់គ្រងទាំងមូលនៃសកម្មភាពនានានៅកម្ពុជា។ ***ក្រាហ្វិកទី ១*** កំណត់នូវតួនាទី និងភាពទទួលខុសត្រូវនៃផ្នែកគ្រប់គ្រងគម្រោង និងផ្នែកអនុវត្តគម្រោង។ ផ្នែកនិមួយៗនឹងកំណត់នូវអ្នកសម្របសម្រួលសុវត្ថិភាពជាសមភាគី និងការបណ្តុះបណ្តាលនឹងត្រូវបានផ្តល់ទៅដល់សមភាគី ក៏ដូចជាមន្ត្រីសំខាន់ៗផ្សេងៗទៀត។

តារាងទី ១. សេចក្តីណែនាំស្តីពីសកម្មភាព និងបញ្ហាសុវត្ថិភាពនានា

| សក្តានុពលប៉ះពាល់ជាអវិជ្ជមាន | សកម្មភាពសម្រាលដែលតម្រូវនានា | កំណត់សំគាល់ |
|---|---|---|
| (១). ការបាត់បង់បណ្តុះអាសន្ន និងអចិន្ត្រៃយ៍ នៃដី រឺធនធានផ្សេងៗសំរាប់គ្រួសារមួយចំនួន រួមទាំងការកំណត់នៃការប្រើប្រាស់ធនធានធម្មជាតិ និង/រឺឧបសគ្គមួយចំនួនលើចលនារបស់មនុស្ស និង សត្វ (រួមទាំងសកម្មភាពល្បាត)។ | កំណត់នូវបរិមាណ និងសភាពនៃដីដែលបាន តម្រូវម្ចាស់ និង/រឺបញ្ហាផ្សេងៗទៀត និងរៀបចំផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញដើម្បីផ្តល់នូវសំណង និងជំនួយទៅតាមគម្រោងគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញសំរាប់កម្ពុជា។<br>គម្រោងនឹងគាំទ្រដើម្បីបង្កើនការយល់ដឹងនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់នានានូវយន្តការសារទុក្ខ និងកសាងសមត្ថភាពទៅលើយន្តការសារសារទុក្ខដែលមានស្រាប់ស្តីពីកិច្ចការដែលបានតម្រូវព្រមទាំងការដោះស្រាយ និងចរចារការតវ៉ា-កត់ត្រា និងរាយការណ៍ និងត្រួតពិនិត្យដំណោះស្រាយដែលបានស្នើ | កិច្ចពិគ្រោះយោបល់លើកតំបូងជាមួយធនាគារពិភពលោក ការរៀបចំឯកសារ និងការសង្ខេបដោយធនគារពិភពលោកអាចមានភាពចាំបាច់ |
| (២). ជលោះសង្គមដែលអាចកើតមាននានាលើកម្មសិទ្ធិដី និងបញ្ហាប្រើប្រាស់ដី និងសិទ្ធិទទួលទឹកផ្គត់ផ្គង់ និងជំលោះសង្គមនានា | អភិវឌ្ឍន៍វិធានការសម្រាលសំរាប់ដំណោះស្រាយជំលោះតាមរយៈកិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទស្នាលជាមួយអ្នកពាក់ព័ន្ធនានា និងដាក់នៅក្នុងដំណើការរបស់គម្រោង ដែលជាប់ទាក់ទងទៅនឹងសហគមន៍ដែលពឹងទៅលើការគ្រប់គ្រងរួមគ្នាដោយមិនរារាំងភាពពាក់ព័ន្ធនៃក្រុមទី ៣/អ្នកសម្រុះសម្រួលពីខាងក្រៅ<br>អភិវឌ្ឍន៍កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ធនធាននៅតាមភូមិ<br>ប្រើប្រាស់យន្តការគ្រប់គ្រងជំលោះនៅតាមមូលដ្ឋានដែលមានស្រាប់ ដែលទំនងជាដឹកនាំដោយចាស់ព្រឹទ្ធាចារ្យ និងអ្នកដែលគេគោរព រឺមេដឹកនាំនៃជនជាតិដើមភាគតិច រឺជនជាតិភាគតិច | ប្រសិនបើជំលោះនានាអាចធ្វើអោយកាន់តែលំបាកដល់ជីវភាព និងលក្ខខណ្ឌការរស់នៅរបស់ស្ត្រី រឺគ្រួសារដែលមានជីវភាពក្រីក្រ នៅក្នុងតំបន់អនុគម្រោង រឺទំនងជិតតែ ធ្ងន់ធ្ងរឡើង នោះត្រូវបង្ហាញទៅដល់ធនាគារពិភពលោក។ |

| | | |
|---|---|---|
| (៣). ទំនងជាមានផលប៉ះពាល់ទៅលើជនជាតិដើមភាគតិច | អនុវត្តដំណើការវាយតម្លៃសង្គមតាមរយៈដោយសេរី តំបូង និងកិច្ចពិគ្រោះយោបលដែលបានជូនដំណឹង និងប្រសិនបើចាំបាច់ រៀបចំផែនការអភិវឌ្ឍន៏ជនជាតិដើមភាគតិចអោយស្របទៅតាមការណែនាំរបស់ គម្រោងអភិវឌ្ឍន៏ ជនជាតិដើមភាគតិចនៅកម្ពុជា។<br>គម្រោងនឹងគាំទ្រដើម្បីបង្កើនការយល់ដឹងនៃប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ ទៅតាមភាសាដើមរបស់ក្រុមពួកគេ អំពីយន្តការសារទុក្ខ និងការកសាងសមត្ថភាពទៅលើយន្តការសារទុក្ខដែលមានស្រាប់ស្តីពីភារកិច្ចដែលបានតម្រូវ រួមទាំងការដោះស្រាយ រឺចរចារការតវ៉ាពីជនជាតិដើមភាគតិច រឺជនជាតិភាគតិច និងត្រួតពិនិត្យលើដំណោះស្រាយដែលបានស្នើឡើង។ | កិច្ចពិគ្រោះយោបល់លើកតំបូងជាមួយធនាគារពិភពលោក ឯកសារគ្រប់គ្រាន់ និងការសង្ខេបសំខាន់ៗតាមរយៈធនាគារពិភពលោកអាចជាការចាំបាច់។ |
| (៤). ទំនងជាបង្កើននូវការប្រើប្រាស់ថ្នាំសំលាប់ សត្វចង្រៃ និងសារធាតុពុលគីមីនានាដែលអាចប៉ះពាល់ដល់គុណភាពដី ទឹកនិងអ្នកប្រើប្រាស់ទឹកផ្ទៃលខាងក្រោម។ | ហាមឃាត់ក្នុងការប្រើប្រាស់បរិមាណច្រើននៃថ្នាំសំលាប់សត្វចង្រៃ និងសារធាតុពុលគីមី ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីកសិដ្ឋានសរីរាង្គ និងការគ្រប់គ្រងសត្វចង្រៃចម្រុះ និងការប្រើប្រាស់ប្រកបដោយសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតខណៈដែលចាំបាច់។ | |
| (៥). សកម្មភាពនានាត្រូវបានអនុវត្តនៅក្នុងតំបន់ការពារ កន្លែងអភិរក្សសត្វ តំបន់ទ្រនប់ តំបន់ដីសើម រឺតំបន់អភិរក្សផ្សេងៗទៀត រឺសកម្មភាពនានាដែលពាក់ព័ន្ធការងារសង្គមមួយចំនួនដែលអាចប៉ះពាល់ទៅដល់បរិយាកាស សំលេង និងការបំពុលទឹក ច្រោះដី និង បង្កអោយមានផលប៉ះពាល់សុខមាលភាពសារធារណៈ ការបរបាញ់សត្វព្រៃ រឺផលប៉ះពាល់ទៅ | • រៀបចំផែនការគ្រប់គ្រងបរិស្ថានដើម្បីសម្រាលផលប៉ះពាល់ជាអវិជ្ជមានដែលអាចមាននានា និងដើម្បីកាត់បន្ថយសុវត្ថិភាពគ្រោះថ្នាក់ ការណែនាំស្តីពីវិធានការសម្រាលនានាគួរត្រូវបានផ្តល់អោយនៅសៀវភៅប្រតិបត្តិសុវត្ថិភាព។<br><br>• រៀបចំពិគ្រោះយោបល់ជាមួយអាជ្ញាធរ និងសហគមន៏នានា | ផ្នែកការអនុវត្តគម្រោង និងផ្នែកគ្រប់គ្រងគម្រោងនឹងធានាថាសកម្មភាពនានាស្របទៅតាមច្បាប់នានារបស់រាជរដ្ឋាភិបាល។<br><br>កិច្ចពិគ្រោះយោបល់លើកតំបូងជាមួយធនាគារពិភពលោក ឯកសារគ្រប់គ្រាន់ និងការសង្ខេបសំខាន់ៗតាមរយៈធនាគារ |

| | | |
|---|---|---|
| ដល់ការប្រើប្រាស់ទឹកនៅផ្នែកខាងក្រោម។ | • អនុវត្តសកម្មភាពនានានៅតាមតំបនលវាំសារដោយស្របទៅតាមផែនការគ្រប់គ្រងរបស់តំបន់វាំសារ និងពិគេគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរគ្រប់គ្រង។ | ពិភពលោកអាចជាការចាំបាច់។ធនាគារពិភពលោក |
| (៦). ការប្រើប្រាស់ព្រៃឈើដោយមានការយល់ដឹង រួមទាំងអនុផលព្រៃឈើ ការបង្ហាញនូវប្រភេទដែលមិនមែនជាប្រភេទក្នុងស្រុក ការបណ្តុលអោយលិចទៅកាន់តំបន់ជិត១ និងការរារាំងដំណើចរាចររបស់ត្រីរួមទាំងការប្រើប្រាស់ដែលមិនមាននិរន្តរភាពនៃប្រភេទនៃវារីសត្វផ្សេងទៀត។ | ពិគ្រោះយោបល់ជាមួយសហគមន៍នៅតាមមូលដ្ឋានដើម្បីខិតទៅរកការព្រមព្រៀងនូវអ្វីដែលជៀសវាង និងសម្រាលលើផលប៉ះពាល់ជាអវិជ្ជមាន និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពបង្កើនឡើងនៃផលិតផលព្រៃឈើ ជលផលនានា និងវារីសត្វផ្សេង១ទៀត។ ប្រសិនបើប្រភេទថ្មីត្រូវបានជាប់ទាក់ទងត្រូវប្រាកដថា ប្រភេទថ្មីនោះគឺមានវត្តមានរួចជាស្រេចនៅក្នុងបរិវេណជិតខាង រឺត្រូវបានគេស្គាល់ថាមិនមានការវាតទីទៅលើប្រភេទដីទៃ។ ប្រសិនបើមានការកំណត់ទៅលើធនធានធម្មជាតិនានា ជំលោះសង្គម និងក្រុមជនជាតិភាគតិចដូចដែលបានបង្ហាញនៅក្នុងទី ១ ទី ២ ទី ៣ បន្ទាប់មកវិធានការសម្រាលបានកំណត់នៅក្នុង ទី ១ ទី២ និងទី ៣។ | រួមទាំងការកាប់ព្រៃឈើ ការប្រមូលផល រឺការកែឆ្នៃនៃផលិតផលព្រៃឈើ<br>កិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទជាមួយអ្នកជំនាញសុវត្ថិភាពធនាគារពិភពលោកគឺត្រូវបានណែនាំ។ |
| (៧). ជាប់ពាក់ព័ន្ធនិងភាពគ្រោះថ្នាក់នៃយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | ប្រសិនបើមាន ទាក់ទងជាមួយភ្នាក់ងារដែលទទួលខុសត្រូវ និងសំអាតអោយអស់មុនពេលគម្រោងចាប់ផ្តើមសកម្មភាព។ | ផ្នែកអនុវត្តគម្រោងដឹកនាំនៅក្នុងការរក្សាសុវត្ថិភាពនៃតំបន់របស់គម្រោង |
| (៨). សកម្មភាពពាក់ព័ន្ធនានាទៅនឹងការងារសង្គមស៊ីវិលតូច១ដែលអាចប៉ះពាល់លើ បរិមាណខ្យល់តិចតួច សំលេង និងបំពុលដល់ទឹក វិចរឹលដី និងគ្រោះថ្នាក់ ការប្រមាញ់សត្វព្រៃ រឺផលប៉ះពាល់នានាទៅលើការប្រើប្រាស់ទឹកនៅផ្នែកខាងក្រោម។<br>៩. ឱកាសដើម្បីពង្រឹងផលប្រយោជន៍បរិស្ថាន បញ្ហា | • អនុវត្តវិស្វកម្មល្អ១ និងគេហកិច្ចល្អ១ជាមួយការគ្រប់គ្រង និងតាមដានយ៉ាងលំអិត រួមទាំងការរក្សានូវការពិគ្រោះយោបល់ជាមួយប្រជាជននៅតាមមូលដ្ឋាន។<br>• The contract will also include a special clause on *“chance find”*.<br>• កិច្ចសន្យានឹងត្រូវរួមញ្ចូលទាំងអនុប្រយោគស្តី | ផ្នែកគ្រប់គ្រង និងអនុវត្តគម្រោងនឹងធានាថាវិធានការសម្រាលដែលល្អ១គឺត្រូវបានរួមបញ្ចូលនៅក្នុងកិចសន្យា និងម្ចាស់កិច្ចសន្យានោះអនុវតពួកវាប្រកបដោយប្រសិទ្ធភាព។<br>ទាំងនេះដើម្បីពង្រឹងផលប៉ះពាល់ជា |

| | | |
|---|---|---|
| នានាទាក់ទងទៅនឹងទន្លេមេគង្គខាងលើ និងរួមគ្នាជាមួយសកម្មភាពនានារបស់គណៈគម្មការទន្លេមេគង្គ | ពី "ការរកឃើញនៃឱកាស"<br>• សហការណ៍យ៉ាងជិតស្និទ្ធជាមួយបណ្តាប្រទេស និង គណៈគម្មការទន្លេមេគង្គក្នុងកំលុងពេលអនុវត្តគម្រោង។ | វិជ្ជមាននៃគម្រោង។ |

ក្រាហ្វិកទី ១- ក្រាហ្វិកដើម្បីកំណត់នូវវិធានការសុវត្ថិភាព



## ***ឧបសម្ព័ន្ធទី ១: បញ្ជីនៃផលប៉ះពាល់ជាអវិជ្ជមាននៃសកម្មភាពនានាដែលត្រូវបានហាមឃាត់***

ដើម្បីជៀសវាងនូវផលប៉ះពាល់ជាអវិជ្ជមានលើមនុស្ស និងបរិស្ថាន សកម្មភាពបន្ទាប់មួមចំនួនត្រូវបានដាក់បញ្ចូលជាក់ស្តែងពីថវិការដែលស្ថិតនៅក្រោមគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ :

(១). ការតាំងលំនៅថ្មី និងការកំទេចចោលរចនាសម្ព័ន្ធនៃលំនៅដ្ឋាន រឺមុខរបរផ្សេងៗ។

(២). ការផ្តល់ដីដែលប៉ះពាល់ដល់ប្រជាពលរដ្ឋជាង ២០០ នាក់ រឺ ៤០ គ្រួសារ។

(៣). ការតាំងលំនៅដ្ឋានថ្មី រឺការពង្រីកនៃលំនៅដ្ឋានដែលមានស្រាប់នៅក្នុងជម្រកសុវត្ថិភាពធម្មជាតិ និងមានស្រាប់ រឺតំបន់ដែលបានដាក់ស្នើជាតំបន់ការពារ។

(៤). ទំនងជាបង្កើនឡើងនូវផលប៉ះពាល់ជាអវិជ្ជមានទៅលើក្រុមជនជាតិភាគតិចនៅក្នុងភូមិ និងនៅតាមបណ្តាភូមិជិតខាង រឺដែលមិនទទួលយកពីក្រុមជនជាតិដើមភាគតិចកំពុងរស់នៅក្នុងភូមិដែលនៅលាយលំគ្នាជាមួយជនជាតិដ៏ទៃទៀត។

(៥). ភាពបាត់បង់ រឺការខូចខាតទៅលើសម្បត្តិប្រពៃណី រួមទាំងទីតាំងនានាដែលមានតម្លៃតាំងពីបូរាណ វិទ្យាសាស្ត្រនៃការអានអក្សរបូរាណ ប្រវត្តិសាស្ត្រ សាសនា វប្បធរដែលមានលក្ខណៈពិសេស។

(៦). ផ្លូវថ្មីនានា ការស្ថាបនាផ្លូវឡើងវិញ ផ្នែកខាងលើផ្លូវ រឺការធ្វើបច្ចុប្បន្នភាពឡើងវិញនៃរាល់សកម្មភាពនៅក្នុងជម្រកសុវត្ថិភាពធម្មជាតិនានា និងដែលមានស្រាប់ រឺតំបន់ដែលបានដាក់ស្នើជាតំបន់ការពារ។

(៧). ការទិញម៉ាស៊ីនសាំង រឺម៉ាស៊ូត និងម៉ាស៊ីនបូមទឹក កាំភ្លើង រណារច្រវ៉ាក់ បរិមាណច្រើននៃថ្នាំសំលាប់សត្វចង្រៃ ថ្នាំសំលាប់សត្វល្អិត ថ្នាំសំលាប់រុក្ខជាតិ និងថ្នាំគីមីដែលមានគ្រោះថ្នាក់ផ្សេងៗទៀត សារធាតុមិនឆេះ និងការវិនិយោគដែលធ្វើអោយខូចខាតដល់បរិស្ថានផ្សេងៗទៀត។ ប្រសិនបើប្រភេទសត្វចង្រៃកើតឡើង បរិមាណតិចនៃការលើកទឹកចិត្ត និងថ្នាំសំលាប់សត្វចង្រៃដែលបានចុះបញ្ជីនៅក្នុងប្រទេសឡាវអាចត្រូវបានអនុញ្ញាត្តិ។

(៨). ការប្រតិបត្តិព្រៃឈើ រួមទាំងការកាប់ឈើ ការកែច្នៃ និងប្រមូលផលនៃផលិតផលព្រៃឈើទោះជាយ៉ាងណា នោះការគាំទ្រដើម្បីអោយមាននិរន្តរភាពលើការកែច្នៃ និងប្រមូលផលនៃអនុផលព្រៃឈើត្រូវបានអនុញ្ញាត្តិ ប្រសិនបើស្របទៅតាមផែនការគ្រប់គ្រងសំរាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិ។

(៩). វត្ថុមាននៃប្រភេទក្រៅស្រុក លើកលែងតែប្រភេទទាំងនេះមានវត្ថុមានរួចជាស្រេចនៅក្នុងតំបន់ក្បែរៗ រឺត្រូវបានគេស្គាល់ថាមានលក្ខណៈស្រដៀងទៅនឹងប្រភេទដែលមិនរាតត្បាតទៅលើប្រភេទដទៃទៀត។

(១០). ការកែប្រែសំខាន់ៗ រឺការថយចុះនៃជម្រកសុវត្ថិភាពធម្មជាតិ រឺដែលការអភិរក្ស និងការកើនឡើងនៃបរិស្ថានមិនច្បាស់ជាសំខាន់ជាងទៅលើសក្តានុពលនៃការបាត់បង់នោះទេ។

(១០). ការសាងសង់ដែលមានទ្រង់ទ្រាយធំ រឺតូចៗ/មធ្យមត្រូវបានគេសង្ឃឹមថានាំអោយមានផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន។ គម្រោងធំៗតម្រូវអោយមានការសិក្សាការវាយតម្លៃផលប៉ះពាល់បរិស្ថាន នោះមិនត្រូវបានផ្តល់ថវិការនោះទេ។

## ឧបសម្ព័ន្ធទី ២: ការអនុវត្តវិស្វកម្មល្អៗ និងវិធានការសម្រាលមួយចំនួន

### ២.១. ការអនុវត្តគេហកិច្ច និងការអនុវត្តវិស្វកម្មល្អៗ

ការអនុវត្តនៃគេហកិច្ចដែលទាក់ទងទៅនឹងការស្តុកទុក ការប្រើប្រាស់ សំអាត និងការបោះចោលដែលមានលក្ខណៈត្រឹមត្រូវនៃសម្ភារៈផ្សេងៗដែលបានប្រើក្នុងកំលុងពេលនៃការសាងសង់សំរាប់សុវត្ថិភាពមនុស្ស និងបរិស្ថាន។ ការអនុវត្តគេហកិច្ចដែលប្រពៃខាងក្រោមត្រូវបានតម្រូវអោយសំរាប់សកម្មភាពថវិការរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គៈ

### ប្រការគួរធ្វើៈ

១. ម៉ោងធ្វើការដែលបានកំណត់ក្នុងកំលុងពេលថ្ងៃ ជាពិសេសនៅតាមទីតាំងរស់នៅ និងកាត់បន្ថយល្បឿននៃការបើកបរ។

២. កាត់បន្ថយការជីកដី និងការចោលកាកសំណល់

៣.កាត់បន្ថយការជីករណ្តៅថ្មីៗ និងប្រាកដថាមានទីតាំងនៅក្បែរៗ

៤. កាត់បន្ថយការកកស្ទះចរាចរណ៍ ធូលី និងសំលេង

៥. រក្សាអោយបានត្រឹមត្រូវនៃសម្ភារៈសំណង់ និងយាន្តយន្តធំៗ

៦. ផ្តល់នូវស្លាកសញ្ញាសុវត្ថិភាពអោយបានត្រឹមត្រូវ (ថ្ងៃ និងយប់) និងប្រាប់អោយបានល្អទៅដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

៧. ជៀសវាងការកំពុបនៃការប្រើប្រាស់ប្រេង និងសម្ភារៈពុលផ្សេងៗទៀត រួមទាំងសុវត្ថិភាពនៃការដឹកជញ្ជូន និងការដាក់ស្តុក ។

៨. អនុវត្តគេហកិច្ចអោយបានល្អនៅក្នុងការសាងសង់ និងទីតាំងស្តុកទុកទំនិញ ដើម្បីធានាថាសុវត្ថិភាពនៃអ្នកធ្វើការ (កម្មករ) និងប្រជាពលរដ្ឋ (ដាក់សំរាមនៅមួយកន្លែង និងប្រមូលទៅដាក់កន្លែងធ្វើការអោយមានរបៀប និងមានសុវត្ថិភាព អនុវត្ត និងរៀបចំការបោះបង់អោយបានត្រឹមត្រូវ កាកសំណល់ និងសម្ភារៈផ្សេងៗទៀត រក្សាទីតាំងធ្វើការ និងរាល់សម្ភារៈអោយរៀបរយ ។ មានទីតាំងជ្រើសរើសទុកជាមុនសំរាប់ចោលសម្ភារៈសំណល់ផ្សេងៗ និងផ្តល់នូវធុងសំរាម រក្សានូវជណ្តើរ ផ្លូវចេញចូល និងជណ្តើរសេរីសំរាប់សម្ភារៈ ផ្គត់ផ្គង់ និងការរាំងសុវត្ថិភាព និងសម្ភារៈពន្លឺនានាដែលបានដាក់ទុកនៅលើតំបូល រឺកន្លែងបើកចំហរ រក្សាទុកនូវសម្ភារៈយ៉ាងហោចកំពស់ ២ ម៉ែត្រ ( ២ ហ្វីត) ពីកន្លែងចំហរ ជ្រុងនៃតំបូល ដីក្រហួង និងស្នាមភ្លោះនានា យកចេញ រឺដែកគោលកោងដែលលយចេញ ពីឈើ រក្សាទុយ៉ូទឹក ខ្សែពួរដែលមានជាតិម្សៅ.....។ល។ ពីកន្លែងទឹកន្លែងដើរចេញចូល រឺទីតាំងផ្សេងៗ។ ធានាថា ការជីក រឺរណ្តៅត្រូវបានគ្រប និងការពារបានប្រសើរ ផ្តល់នូវប្រដាប់ការបារអគ្គីភ័យ ។ រក្សានូវស្ថានីយ៍ពន្លត់អគ្គីភ័យ អោយបានច្បាស់លាស់ និងនៅជិតៗ.....។ល។

៩. ប្រាកដថាមានទឹកស្អាត និងបង្គន់អនាម័យសំរាប់កម្មករ និងផ្តល់នូវមុង។

១០. ជៀសវាងជំលោះវប្បធម៌ និងសង្គមរវាងកម្មករ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន

**ប្រការមិនគួរធ្វើៈ**

(១). មិនអនុញ្ញាត្តិអោយចោលសំរាមដោយសេរីពីទីតាំងនានានៃគម្រោង និងប្រើប្រាស់តាមរយៈពពួកសត្វនានា (ឆ្កែ ឆ្មារ ជ្រូក....។ល។) ។ ត្រូវប្រើប្រាស់ធុងសំរាមអោយបានប្រសើរ ។

(២). មិនចោលសម្ភារៈ រឺរបស់ផ្សេងៗទៀត

(៣). មិនបង្កើន រឺបន្ថយនូវរាល់សម្ភារៈ រឺរបស់ ដូចជាខ្សែលួស រឺទុយ៉ូផ្គត់ផ្គង់

(៤). ប្រើនូវប្រដាប់គ្របដីអោយរឹងមាំដើម្បីការពារអគ្គីសនីអាកាសកើតមាន

(៥). កម្មករមិនអនុញ្ញាត្តិអោយមានការបាញ់សត្វព្រៃនៅតាមតំបន់ការពារនានា

**កំណត់សំគាល់សំខាន់ៗស្តីពីសម្ភារៈដែលអាចផ្ទុះ និងឆាបឆេះមួយចំនួនៈ**

១. ដាក់សម្ភារៈដែលអាចផ្ទុះ និងដែលអាចឆាបឆេះមួយចំនួន ដូចជាប្រេងម៉ាស៊ូត ប្រេងផ្សេងៗ និងផ្នែកសំអាតពីសម្ភារៈដ៏ទៃទៀត។

២. រក្សាសម្ភារៈដែលអាចផ្ទុះ និងដែលអាចឆាបឆេះបាននៅក្នុងធុងអោយបានត្រឹមត្រូវដែលមានឈ្មោះ និងបិទតែមអោយបានល្អ។

៣. បោះបង់ចោលនូវរបស់ដែលមានប្រេងច្រើន ប្រេង និងសម្ភារៈដែលអាចឆេះផ្សេងៗទៀតនៅក្នុងធុង

៤. ស្តុកទុកនូវធុងនៅក្នុងទីតាំងឈរត្រង់ (ដាក់អោយត្រង់)

៥. ស្តុកទុកធុងទទេនៅដាច់ដោយឡែក

៦. ដាក់សញ្ញាសំគាល់ស្តីពីការហាមឃាត់នូវការពិសារបារី ប្រភពអណ្តាតភ្លើង និងការឆេះឡើងនៅតាមតំបន់នានាដែលមានសម្ភារៈអាចឆាបឆេះ និងផ្ទុះឡើងដែលបានប្រើប្រាស់ និងដាក់ទុក។

៧. ស្តុកទុក និងដាក់គន្លឹះនូវរាល់ធុងឧស្ម័នអោយនៅឈរត្រង់

៨. ដាក់ស្លាកសញ្ញាលើបំពង់/ធុងទទេ និងដាក់ពួកវានៅដោយឡែកពីធុងដែលពេញ រឺមានឧស្ម័នខ្លះៗ។

៩. បញ្ចូលខ្យល់ទៅរាល់កន្លែងស្តុកអោយបានត្រឹមត្រូវ

១០. ប្រាកដថារាល់កុងតាក់ត្រូវភ្លើងមិនងាយផ្ទុះនៅពេលដែលសម្ភារៈដែលអាចឆាបឆេះត្រូវបានស្តុកទុក

២.២. ខាងក្រោមជានីតិវិធី " ការរកឃើញ" ដើម្បីរួមបញ្ចូលនៅក្នុងកិច្ចសន្យាការងារស៊ីវិលៈ

ប្រសិនបើម្ចាស់កិច្ចសន្យារកឃើញនូវទីតាំងបូរាណ ប្រវត្តិសាស្រ្ត នៅមាន និងមិនយល់ស្រប រួមទាំងសួនច្បារផ្នូរសាកសពបូរាណ/ ផ្នូរសាកសពបុគ្គលក្នុងកំលុងពេលនៃការជីក រឺសាងសង់ ម្ចាស់កិច្ចសន្យាគួរៈ

- បញ្ឈប់សកម្មភាពសាងសង់នៅក្នុងតំបន់នៃការរកឃើញថាមានគ្រោះអះថ្នាក់
- រៀបរាប់នូវទីតាំង រឺតំបន់ដែលបានរកឃើញ
- រក្សាទីតាំងដើម្បីការពារនូវបញ្ហាខូចខាតនានា រឺការបាត់បង់នៃការជំទាស់ដែលបង្កឡើងដោយសារការយកចេញ។ ក្នុងករណីខ្លះនៃការបន្សល់ទុកនូវរបស់បូរាណដែលផ្លាស់ចេញ ការយាមនៅពេលយប់គួរត្រូវរៀបចំរហូតដល់ភាពទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន រឺរដ្ឋបាលវប្បធមិជាតិទទួលខុសត្រូវ។
- ប្រាប់ជាផ្លូវការដល់មន្រ្តីបរិស្ថានគម្រោង និងគម្រោងវិស្វកម្មដែលអន្តេវេសិកនឹងប្រាប់ទៅដល់អាជ្ញាធរមូលដ្ឋានដែលទទួលខុត្រូវ និងមន្ទីរវប្បធមិខេត្តអោយបានលឿន (ក្នុងរយៈពេល ២៤ ម៉ោង រឺតិចជាងនេះ)។

- មន្ទីរវប្បធម៌ខេត្ត និងអាជ្ញាធរមូលដ្ឋានទទួលខុសត្រូវ គួរទទួលខុសត្រូវលើការថែរក្សា និងការពារទីតាំងមុនពេលការសម្រេចចិត្តលើនីតិវិធីសមស្របនៃអនុគម្រោង។ នេះគួរតែតម្រូវអោយមានការវាយតម្លៃជាបឋមនៃការរកឃើញ ដែលត្រូវបានបង្កើតឡើងដោយអ្នកបូរាណវិទ្យានៃរដ្ឋបាលវប្បធម៌ជាតិ។ សារៈសំខាន់នៃការរកឃើញនានាគួរផ្អែកត្រូវបានវាយតម្លៃដោយផ្អែកទៅលើលក្ខខណ្ឌមរតកវប្បធម៌ ទាំងនោះរួមមាន សិល្បៈវិជ្ជា ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ រឺការស្រាវជ្រាវ តម្លៃសេដ្ឋកិច្ច និងសង្គម។
- ការសម្រេចចិត្តពីរបៀបដើម្បីបកស្រាយនៃការរកឃើញគួរត្រូវបានអនុវត្តដោយអាជ្ញាធរទទួលខុសត្រូវ និងមន្ទីរវប្បធម៌ខេត្ត។ នេះគួរតែរួមបញ្ចូលទាំងការផ្លាស់ប្តូរនៅក្នុងការរៀបចំ (ដូចជាខណៈដែលការរកឃើញរបស់ដែលនៅមិនបានយកចេញបានដូចជាវប្បធម៌ រឺបូរាណវិទ្យាសំខាន់ៗ) ការអភិរក្ស ការបង្ការ ការស្តារឡើងវិញ និងការជួយស្រោចស្រង់។
- ការអនុវត្តសំរាប់ការសម្រេចចិត្តរបស់អាជ្ញាធរទាក់ទងទៅនឹងការគ្រប់គ្រងនៃការរកឃើញគួរត្រូវបានទាក់ទងទៅក្នុងការសរសេរតាមរយៈអាជ្ញាធរមូលដ្ឋានមួយចំនួន និង
- ការងារសាងសង់គួរចាប់ធ្វើបន្តបន្ទាប់ពីការអនុញ្ញាតិត្រូវបានផ្តល់អោយដោយអាជ្ញាធរមូលដ្ឋាន រឺមន្ទីរវប្បធម៌ខេត្តទាក់ទងទៅនឹងសុវត្ថិភាពនៃមរតក។

### ២.៣. ភាពប៉ះពាល់បរិស្ថាន និងវិធានការសម្រាលសំរាប់សំណង់សាធារណៈតូចៗ រួមទាំងស្ថានីយ៍ភ្ញាស់កូនត្រី

| **សកម្មភាព** | **សក្តានុពលនៃផលប៉ះពាល់** | **វិធានការសម្រាលដែលអាចមាន** |
|---|---|---|
| *I.* ***ការសាងសង់*** | | |
| 1. ការជំរះទីតាំង | ការរំខាននៃជម្រក និងនៅជិត/ក្បែរសហគមន៍ | បញ្ជាក់ទៅដល់សហគមន៍នៅក្បែរ និងអាជ្ញាធរមូលដ្ឋាន |
| ២. ការងារស៊ីវិលនៅតាមអាគារ | សំលេង ធូលី ការរញ្ជួរ ចរាចរកាកសំណល់ ការបង្កើតនៃអន្លង់នានា | វិធានការកាត់បន្ថយការធ្វើចរាចរ ត្រួតពិនិត្យសំលេង ធូលី រំញ័រ ការឈូសដីដាំដើមឈើលំអរ |
| *II.* ***ការប្រតិបត្តិ*** | | |
| ១. សំរាមពីការសាងសង់អាគារ | ការបំពុលទឹក សំរាម | ប្រាកដថាការចម្រោះការសំណល់ និងការប្រមូល |

| | | |
|---|---|---|
| និងស្ថានីយ៍ភ្ញាស់កូនត្រី | | សំរាមបានល្អ |

## ២.៤ ផលប៉ះពាល់បរិស្ថាន និងវិធានការសម្រាលសំរាប់រណ្តៅជ្រៅៗ

| សកម្មភាព | សក្តានុពលនៃផលប៉ះពាល់ | វិធានការសម្រាលដែលអាចមាន |
|---|---|---|
| ទីតាំង | ការបាត់បង់នៃដី<br>ការខូចខាតដី<br>ផលប៉ះពាល់លើសោភណ័ភាព និងការរំខាន | ការពិគ្រោះយោបល់ជាមួយសហគមន៏ ការផ្តល់ដី ការឈូសឆាយដីដាំដើមឈើលំអរ<br>(ការដាំដើមឈើ/ដំណាំហូបផ្លែ) |
| ការខួង | ការរំខានដល់ព្រៃក-អូរ និងវារីសត្វ<br>ការរំខានសង្គមដោយសារកម្មករសំណង់<br>ភាពគ្រោះថ្នាក់នានារបស់ការសាងសង់<br>ប្រភេទជំងឺថ្មីៗ | ការដាំរុក្ខជាតិឡើងវិញ បង្កើតទីតាំងភូមិលំនៅឡើងវិញសំរាប់កម្មករនៅក្រៅភូមិ ដើម្បីសម្រាលឥទ្ធិពលសង្គមទៅវិញទៅមក |
| ការតម្លើងម៉ាស៊ីនបូមទឹក | ទឹកក្រោមដី និងទឹកនៅលើដីមានបរិមាណប្រេង/ខ្លាញ់ .....។ល។ | អ្នកខួងអណ្តូងដែលមានបទពិសោអន៏គ្រាប់តែនីតិវិធីសុវត្ថិភាពគំរូ |
| ការប្រតិបត្តិ | អាងទឹក/បឹងអាចជាតំបន់បន្តពូជសំរាប់ទឹក/ការកើតឡើងនៃជំងឺរ៉ាកទ័រ (ដង្កូវ មូស) ទឹកអាចត្រូវបានចម្លងមេរោគក្នុងកំលុងពេលនៃការដឹកជញ្ជូន រឺរក្សាទុក លិច រឺជ្រាបនៃការចម្លងរោគនៃទឹក ការកាត់បន្ថយនូវគុណភាពទឹកដោយសារសារធាតុដែលធ្វើអោយរលួយ ការបូមទឹកក្រោមដីលើសកម្រិតបណ្តាលអោយធ្វើអោយស្រកនៃទឹកក្រោម ដែលរំខានដល់ជលវិទ្យាផ្នែកខាងក្រោម។ | សហការណ៏កម្មវិធីបណ្តុះបណ្តាលអនាម័យ និងសុខភាពធានាថាការផ្តល់គ្រប់គ្រាន់នូវការគ្រប់គ្រាន់និងរក្សានៃការសម្របសម្រួលនានា (រួម ទាំងការបណ្តុះបណ្តាលសហគមន៏ និងមន្ត្រីគ្រប់គ្រាន់ |

**2.5 Environmental effects and mitigation measures for rural roads**

## ២.៥. ផលប៉ះពាល់បរិស្ថាន និងវិធានការសម្រាលសំរាប់ផ្លូវជនបទ

| ជំហាន/សកម្មភាព | សក្តានុពលនៃផលប៉ះពាល់ | វិធានការសម្រាលដែលមាន |
|---|---|---|
| ការរៀបចំ/ផែនការ | គារផ្តល់ដី ការទន្ទ្រានទៅលើតំបន់ការពារ និង ជម្រកធម្មជាតិ តំបន់វប្បធម៌... ។ល។<br>កម្រិតស្តង់ដាខ្ពស់ពេក និងការជីកដីបរិមាណច្រើន<br>ជន់ដោយសារការរារាំងនៃប្រឡាយ-អូរ<br>ទីតាំងនៃជំរំ- ការដ្ឋានស្នាក់នៅត្រូវទទួលយល់ព្រមដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន | អនុវត្តតាមស្តង់ដាអោយបានត្រឹមត្រូវ ទំហំ និង ទិសដៅនៃផ្លូវដើម្បីកាត់បន្ថយផលប៉ះពាល់នានា ការជ្រើសរើសផ្លូវគួរត្រូវបានធ្វើតាមរយៈការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅតាមមូលដ្ឋាន សុវត្ថិភាព និងធូលីដីដែលប៉ះពាល់ក្នុងកំលុងពេលនៃការសាងសង់ និងប្រតិបត្តិគួរត្រូវបានយកចិត្តទុកដាក់<br>វិធានការនៃការផ្តល់សំណងមួយចំនួនត្រូវតែបំពេញមុនពេលនៃការចាប់ផ្តើមសាងសង់ |
| ការសាងសង់ | បង្កើនសំលេងរំខាន និងការបំពុលបរិយាកាសនៅជិតទីតាំងស្នាក់នៅ ការនាំមកនូវក្រុមកម្មករដែលមកពីខាងក្រៅ និងផលប៉ះពាល់ផ្សេងៗទៀតទៅលើសង្គម ការរៀបចំកាកសំណល់ពីកន្លែងការដ្ឋានសាងសង់ និងកន្លែងធ្វើការបង្កើននូវការប្រើប្រាស់ខុស និងការប្រមាញ់សត្វព្រៃ និងត្រីដែលគ្មានមិនមានការត្រួតពិនិត្យ ។ បង្កើនការបំពុលពីកន្លែងធ្វើការ( ការដ្ឋាន) បង្កើនភាពគ្រោះថ្នាក់ដោយសារតែសុវត្ថិភាពចរាចរការជីករណ្តៅ...... ។ល។ | ម្ចាស់កម្មសិទ្ធិត្រួតពិនិត្យល្បឿនរថយន្ត និងសំលេង ម្ចាស់កិច្ចសន្យាផ្តល់ការងារដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានតាមដែលអាចធ្វើទៅបាន បង្កើត និងអនុវត្តផែនការគ្រប់គ្រងកាកសំណល់ ម្ចាស់កិច្ចសន្យាផ្គត់ផ្គង់ប្រេងសំរាប់ការចំអិនអាហារ និងកំដៅនៅក្នុងជំរំស្នាក់នៅ និងផ្តល់នូវចំណីអោយបានគ្រប់គ្រាន់ អនុវត្តល្អនូវគេហកិច្ច និងអនុវត្តល្អនូវវិស្វកម្មនៅគ្រប់កន្លែងធ្វើការនិងជំរំស្នាក់នៅ ផ្តល់វិធាន និងស្លាកសញ្ញាផ្លូវដែលមានសុវត្ថិភាពអោយបានត្រឹមត្រូវជ្រើសរើសអោយបានត្រឹមត្រូវនូវរណ្តៅដី និងធនាថាបិទអោយបានត្រឹមត្រូវ ។ |
| ការប្រតិបត្តិ | បង្កើនភាពគ្រោះថ្នាក់ និងធូលីដោយសារ | លើកស្លាកសញ្ញាអោយបានត្រឹមត្រូវ និងសហការណ៍ |

| | | |
|---|---|---|
| | សុវត្ថិភាពដងផ្លូវ | ជាមួយអ្នករស់នៅតាមមូលដ្ឋានអនុវត្តនូវសកម្មភាព ដើម្បីលើកកម្ពស់សុវត្ថិភាពដងផ្លូវ |

## ២.៦. ផលប៉ះពាល់បរិស្ថាន និងវិធានការសម្រាលសំរាប់ (ខ្នាតមធ្យម) គម្រោងធារាសាស្ត្រ

| សក្តានុពលផលប៉ះពាល់ជាអវិជ្ជមាន | វិធានការសម្រាលដែលមាន |
|---|---|
| ការច្រោះដី | រៀបចំអោយបានត្រឹមត្រូវ និងដាក់នូវគន្លង រឺជៀសវាងជំរាលខ្លាំង កម្រិតដី រៀបចំអោយបានរាបស្មើនៅលើទីតាំងទួល/ភ្នំ ដើម្បីកាត់បន្ថយសំណឹតផ្ទៃខាងលើ រក្សានូវរុក្ខជាតិតូចៗគ្របពីលើ ។ |
| ការកាត់ដីដោយសារទឹក | ច្បាប់នៃការត្រួតពិនិត្យទឹកដើម្បីជៀសវាងការប្រើប្រាស់លើសកម្រិត ។<br>ការប្រើប្រាស់ប្រឡាយជាជួរ និងទុយ៉ូដើម្បីការពារការកំពប់ប្រេង ការគណនាត្រឹមត្រូវនៃតម្រូវការធារាសាស្ត្រដែលផ្តល់អោយ ។ |
| សារធាតុអំបិលនៅក្នុងដី | ការច្រោះនៃអំបិលតាមរយៈការបង្ហូរនៃដី ការធ្វើកសិកម្មដែលមានកំរិតអំបិលទាប |
| ការសំអាតប្រឡាយ | រៀបចំប្រព័ន្ធប្រឡាយដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ដោយថៃដន្យ ប្រើប្រាស់ថ្មធ្វើជាទំនប់ប្រឡាយ |
| ការរារាំងប្រឡាយដោយសារកករ | វិធានការដើម្បីកាត់បន្ថយភាពរិចរឹលទៅលើការដ្ឋាន រៀបចំ និងគ្រប់គ្រងប្រឡាយដើម្បីកាត់បន្ថយនូវភាពកករ ការផ្តល់នូវការប្រើប្រាស់ប្រឡាយសំរាប់ការយកចេញស្មៅ និងកករ (កាកសំណល់) មួយចំនួន |
| ការច្រោះនៃសារធាតុចិញ្ចឹមពីដី | ការជៀសវាងនៃការស្រោចទឹកលើសកំណត់ ការផ្លាស់ប្តូរនៃសារធាតុបំរុងតាមរយៈការដាំដុះដំណាំឆ្លាស់គ្នា ការគណនាត្រឹមត្រូវនូវតម្រូវការនៃការប្រើប្រាស់ដី |

| | |
|---|---|
| ការរីកសាយភាយនៃអាហ្គេ និងពពួលស្មៅ ដែលងាយសាយកូន | ការត្រួតពិនិត្យលើជីគីមីអោយបានត្រឹមត្រូវ (គុណភាព បរិមាណ និងពេលវេលា) |
| ការរារាំង/ទប់ស្កាត់ប្រឡាយដោយសារស្មៅ | រៀបចំ និងគ្រប់គ្រងប្រឡាយដើម្បីកាត់បន្ថយការលូតលាស់នៃស្មៅ ការផ្តល់នូវការប្រើប្រាស់ប្រឡាយដើម្បីសំអាតស្មៅចេញ |
| ការធ្វើអោយខូចនៃគុណភាពទន្លេដែលស្ថិតននៅខាងក្រោមនៃអនុគម្រោងធារាសាស្ត្រ និងការចម្លងមេរោគនៃទឹកក្រោម ដី (កម្រិតជាតិអំបិលខ្ពស់ សារធាតុបំរុង ការប្រើប្រាស់ជីគីមី កសិកម្ម) បណ្តាលអោយប៉ះពាល់ដល់ជលផល និងអ្នកប្រើ ទឹកផ្នែកខាងក្រោម។ | ការគ្រប់គ្រងទឹកនៅតាមប្រឡាយត្រូវបានលើកកម្ពស់ ការអនុវត្តកសិកម្មត្រូវបានលើកកម្ពស់ និងត្រួតពិនិត្យធាតុចូល (ជាពិសេសជីគីមី និងថ្នាំសំលាប់សត្វល្អិត) ការបង្ខំអោយទទួលនូវលក្ខខ័ណ្ឌគុណភាពទឹក |
| ការកាត់បន្ថយនៃលំហូរផ្នែកខាងក្រោមប៉ះពាល់ទៅលើការប្រើប្រាស់ ប្រៃលិចទឹក អេកូឡូស៊ីព្រៃលិចទឹក ទន្លេ និងជលផលដែសមុទ្រ អ្នកប្រើប្រាស់ទឹក ការលាយឡំគ្នានៃការបំពុល។ | ការតាំងលំនៅដ្ឋាន រឺការរៀបចំឡើងវិញនៃអនុគម្រោងច្បាប់នៃការយកចេញដើម្បីសម្រាលលើផលប៉ះពាល់ វិធាន ការសំណងដែលអាចមាន |
| ការទន្ទ្រានយកដីវាលភក់ និងតបន់ដែលងាយទទួលរងនូវផល ប៉ះពាល់អេកូឡូស៊ី | ជ្រើសរើសនូវទីតាំងអនុគម្រោងដើម្បីជៀសវាង រឺកាត់បន្ថយការទន្ទ្រានយកដីនៅតាមតំបន់សំខាន់ៗ ការបង្កើតនូវកន្លែងផ្តល់សំណង រឺតំបន់ការពារ។ |
| ការគំរាមកំហែងដល់ប្រវត្តិសាស្ត្រ វប្បធម៌ រឺលក្ខណៈសោភ័ណភាព | ជ្រើសរើសទីតាំងអនុគម្រោងដើម្បីការពារភាពបាត់បង់ ការបានមកវិញ រឺការការពារនៃទីតាំងវប្បធម៌ដ៏ទៃទៀត។ |
| ការកែប្រែ រឺភាពបាត់បង់នៃព្រៃលិចទឹក រឺលក្ខណៈសោភ័ណភាព និងការរំខាននៃប្រព័ន្ធអេកូឡូស៊ីនៃតំបន់ឆ្នេរ (ព្រៃកោងកាង) | ការជ្រើសរើសទីតាំងអនុគម្រោងដើម្បីអោយជាតំបន់ដែលមានផលប៉ះពាល់តិចបំផុត ការកំណត់ និងច្បាប់នៃការយកទឹកចេញដើម្បីកាត់បន្ថយបញ្ហានានាដើម្បីពង្រីកភាពដែលអាចទៅរួច។ |
| វត្តមាន រឺភាពដោយថៃដន្យនៃការកើតឡើងនៃជំងឺមួយចំនួននៅក្នុងទឹក | ការប្រើប្រាស់ចង្អូរ រឺទុយ៉ូដើម្បីធ្វើអោយរ៉ិកទ័រងាប់ ការជៀសវាងនៃការទុកទឹកអោយនៅស្ងៀម និងហូរតិចៗ ការតំលើងនូវច្រកទ្វាររបស់ប្រឡាយដើម្បីអនុញ្ញាតិអោយមានការលាង បំពេញ រឺនាំយកនូវរណ្តៅនៅតាមប្រឡាយ និងផ្លូវ។ ការត្រួតពិនិត្យទឹក វិធីបង្ការរោគ និងព្យាបាល។ |

| | |
|---|---|
| ជំងឺ និងបញ្ហាសុខភាពនានាពីការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រទឹកស្អុយ | ចម្រោះទឹកស្អុយ ( ឧ. ស្រះដែលរៀបចំជាមុនដើម្បីប្រើ) ការបង្កើត និងការគោរពលើស្តង់ដាសំរាប់ការប្រើប្រាស់ទឹកស្អុយ ។ |
| ជំលោះទៅលើការប្រើប្រាស់ទឹក និងការគ្មានសមត្ថភាពនៅក្នុងការចែកចាយទឹកទៅតាមតំបន់សេវាកម្ម | គោលបំណងដើម្បីធានាថាការចែកចាយប្រកបដោយសមភាពក្នុងចំណោមអ្នកប្រើប្រាស់ និងតាមដានដើម្បីធានាក្នុងការប្រកាន់ភ្ជាប់ ការបង្កើតឡើងនូវសមាគមអ្នកប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធិភាព |
| ការបូមទឹកក្រោមដីលើសកំណត់ | ការកំណត់នូវការយកចេញដែលវាមិនឈានទៅដល់ " ទិន្នផលសុវត្ថិភាព " ( អត្រានៃការបញ្ចូលឡើងវិញ) |
| ***ផ្នែកពីខាងក្រៅ*** | |
| គុណភាពទឹកដែលបានធ្វើអោយខូច រឺដែលបានធើវអោយមិនអាចប្រើប្រាស់បានដោយសារអ្នកប្រើប្រាស់ដីផ្នែកខាងលើ និងការចាក់បំពេញដោយសារធាតុពុល | ត្រួតពិនិត្យលើការប្រើប្រាស់ដីនៅតាមតំបន់ទីជម្រាល ត្រួតពិនិត្យប្រភពនៃការបំពុល ការចម្រោះទឹកមុនពេលប្រើ |
| ការបរាជ័យនៃទំនប់ផ្នែកខាងលើ រឺបឹង/អាងទឹកដែលសកម្មភាពនានាអនុគម្រោងពឹងលើ | ត្រួតពិនិត្យសុវត្ថិភាពជាមុននូវទំនប់ រឺបឹង/អាងទឹកដើម្បីការអនុវត្តរបស់អនុគម្រោង |